ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**ធនាគារជាតិ នៃ កម្ពុជា**

លេខ ធ១៣.០១៥.៦៨៦ ធ.ស.ក

ភ្នំពេញ ថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១៥

# សេចក្តីជូនដំណឹង

## សន្និសីទម៉ាក្រូសេដ្ឋកិច្ចប្រចាំឆ្នាំលើកទី២ របស់ធនាគារជាតិនៃកម្ពុជា ស្តីពី "ការអភិវឌ្ឍទីផ្សារហិរញ្ញវត្ថុដើម្បីរួមចំណែកលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀល"

ធនាគារជាតិនៃកម្ពុជាមានក្តីសោមនស្សរីករាយសូមជម្រាបជូនដំណឹងដល់សាធារណជនឱ្យបានជ្រាបថា ធនាគារជាតិនៃកម្ពុជានឹងរៀបចំសន្និសីទម៉ាក្រូសេដ្ឋកិច្ចប្រចាំឆ្នាំលើកទី២ ដែលមានបំណងរួមចំណែកពង្រឹងនិងអភិវឌ្ឍសមត្ថភាពស្រាវជ្រាវលើប្រធានបទសំខាន់ៗ ទាក់ទងនឹងការអភិវឌ្ឍសេដ្ឋកិច្ចនិងហិរញ្ញវត្ថុកម្ពុជា និងផ្តល់ឱកាសជូនអ្នករៀបចំគោលនយោបាយ មន្ត្រីជំនាញ អ្នកស្រាវជ្រាវ និងសេដ្ឋវិទូមកពីវិស័យសាធារណៈ ស្ថាប័នហិរញ្ញវត្ថុ គ្រឹះស្ថានឧត្តមសិក្សា និងមជ្ឈមណ្ឌលស្រាវជ្រាវនានា បានជួបពិភាក្សាផ្លាស់ប្តូរយោបល់ និងបទពិសោធន៍អំពីប្រធានបទទាំងនេះ ។ លទ្ធផលនៃសន្និសីទនេះនឹងរួមចំណែកផ្តល់ជាធាតុចូលសម្រាប់ការរៀបចំគោលនយោបាយសេដ្ឋកិច្ច សំដៅបន្តគាំទ្រកំណើនប្រកបដោយចីរភាព ។

ស្របតាមគោលនយោបាយលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀលរបស់រាជរដ្ឋាភិបាល នៅឆ្នាំ២០១៥នេះ ធនាគារជាតិនៃកម្ពុជាបានកំណត់ប្រធានបទសម្រាប់សន្និសីទម៉ាក្រូសេដ្ឋកិច្ចប្រចាំឆ្នាំលើកទី២ នេះស្តីពី "ការអភិវឌ្ឍទីផ្សារហិរញ្ញវត្ថុដើម្បីរួមចំណែកលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀល" ។

លោក លោកស្រី ដែលមានចំណាប់អារម្មណ៍ចូលរួមក្នុងសន្និសីទខាងលើ សូមផ្ញើនូវប្រវត្តិរូបសង្ខេប និងលិខិតបញ្ជាក់ពីគោលបំណងនៃការចូលរួម ព្រមទាំងអត្ថប្រយោជន៍ដែលនឹងទទួលបានពីសន្និសីទនេះ មកកាន់នាយកដ្ឋានស្រាវជ្រាវសេដ្ឋកិច្ចនិងសហប្រតិបត្តិការអន្តរជាតិ ឱ្យបានត្រឹមថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១៥ វេលាម៉ោង ១៥:៤៥ នាទី និងទាក់ទងសម្រាប់ព័ត៌មានបន្ថែមតាមរយៈអ៊ីមែល eric@nbc.org.kh ឬ ទូរស័ព្ទលេខ (+៨៥៥-២៣) ៩៨០ ១៩៦ ។ ដោយកន្លែងមានកំណត់ ធនាគារជាតិនៃកម្ពុជានឹងធ្វើការទាក់ទងទៅកាន់បេក្ខជនចំនួន ១០រូប ដែលនឹងត្រូវជ្រើសរើសឱ្យអញ្ជើញចូលរួមប៉ុណ្ណោះ ។

ទីកន្លែង៖ សណ្ឋាគារសូហ្វីតែលភ្នំពេញភូគីតត្រា
កាលបរិច្ឆេទ៖ ថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០១៥
ពេលវេលា៖ ចាប់ពីម៉ោង ០៨:០០-១៧:០០

**អគ្គនាយកបច្ចេកទេស**

**ជា សិរី**